KHMER

# ប្រព័ន្ធសេវាថែទាំមនុស្សចាស់អូស្ត្រាលី

(THE AUSTRALIAN AGED CARE SYSTEM)



ខណៈដែលពួកគេកាន់តែមានវ័យចាស់ មនុស្សមួយចំនួនអាចមានការលំបាកក្នុងការគ្រប់គ្រងសកម្មភាពប្រចាំថ្ងៃរបស់ខ្លួន។ ក៏ប៉ុន្តែមានសេវាថែ ទាំមនុស្សដែលផ្តល់ជំនួយកម្រិតផ្សេងៗគ្នា ដើម្បីបង្កលក្ខណៈកាន់តែមានភាពងាយស្រួលសម្រាប់មនុស្សចាស់ស្នាក់នៅក្នុងផ្ទះរបស់ខ្លួន។

ជម្រើសមួយទៀតគឺការថែទាំដែលមានលក្ខណៈតាមលំនៅដ្ឋាន ដែលអាចមានលក្ខណៈអចិន្ត្រៃយ៍ ឬមានរយៈពេលខ្លី។

ចំពោះព័ត៌មានបន្ថែមអំពីសេវាទាំងនេះ ឬរបៀបទទួលបានសេវាទាំងនេះ លោកអ្នកអាច៖

- ទូរស័ព្ទទៅ My Aged Care Contact Centre (មជ្ឈមណ្ឌលទំនាក់ទំនងសេវាថែទាំភាពវ័យចាស់របស់ខ្ញុំ) លេខ

  **1800 200 422**

  ចាប់ពីម៉ោង៨ព្រឹក និងម៉ោង៨យប់ ថ្ងៃក្នុងសប្តាហ៍ និងម៉ោង១០ព្រឹក និងម៉ោង២រសៀល រៀងរាល់ថ្ងៃសៅរ៍ ឬ

- ចូលមើលគេហទំព័រ My Aged Care:

  www.**myagedcare**.gov.au

## តើលោកអ្នកត្រូវការអ្នកបកប្រែភាសា ដើម្បីជួយលោកអ្នកធ្វើការហៅទូរស័ព្ទឬទេ?

ប្រសិនបើលោកអ្នកនិយាយភាសាផ្សេងពីភាសាអង់គ្លេស លោកអ្នកអាចទូរស័ព្ទទៅ Translating and Interpreting Services TIS (សេវាបកប្រែភាសាសរសេរ និងនិយាយ) លេខ 131 450។ សូមទូរស័ព្ទ My Aged Care ជាមុនសិន នៅពេលនោះគេនឹងរៀបចំអ្នកបកប្រែ ម្នាក់សម្រាប់លោកអ្នក ឬទូរស័ព្ទទៅ TIS ជាមុនសិន ហើយបន្ទាប់មកស្នើសុំឲ្យគេផ្ទេរលោកអ្នកទៅកាន់សេវា My Aged Care។

## សេវា My Aged Care អាចផ្តល់ជូនព័ត៌មានអំពី៖

- ប្រភេទផ្សេងៗគ្នានៃសេវាថែទាំមនុស្សចាស់
- របៀបស្វែងរកសេវាក្នុងតំបន់ ដើម្បីបំពេញតម្រូវការរបស់លោកអ្នក
- ការចំណាយលើសេវាថែទាំមនុស្សចាស់របស់លោកអ្នក

## ដើម្បី ឲ្យបានដឹងថាតើលោកអ្នកមានសិទ្ធិទទួលបានសេវាឬអត់ បុគ្គលិកនៅ My Aged Care Contact Centre នឹងសួរលោកអ្នកនូវសំណួរ មួយចំនួន ដូចជា៖

- តើបច្ចុប្បន្ននេះ លោកអ្នកកំពុងទទួលបានការផ្គត់ផ្គង់អ្វីខ្លះពីគ្រួសាររបស់លោកអ្នក ឬពីសេវាផ្សេងៗ?
- តើលោកអ្នកមានបញ្ហាសុខភាពអ្វីខ្លះ?
- តើលោកអ្នកចាត់ចែងនៅផ្ទះបានយ៉ាងដូចម្តេចដែរ?

## លោកអ្នកអាចត្រូវការព័ត៌មានមួយចំនួន មុនពេលទូរស័ព្ទទៅ Contact Centre រួមមាន៖

- ព័ត៌មានលម្អិតអំពីប្រាក់សោធន និង Medicare
- ព័ត៌មានទំនាក់ទំនងលម្អិតអំពីមុខអាជីពរបស់លោកអ្នក ឬរបស់សមាជិកគ្រួសារ
- ឈ្មោះរបស់អង្គភាពណាមួយដែលកំពុងផ្តល់សេវាជូនលោកអ្នក (ប្រសិនបើលោកអ្នកកំពុងបានទទួលសេវារួចហើយ)។

បុគ្គលិកនឹងស្នើសុំការយល់ព្រមពីលោកអ្នកដើម្បីបង្កើតកំណត់ត្រាលម្អិតអំពីលោកអ្នក (ឧ. ព័ត៌មានលម្អិតអំពីប្រាក់សោធន និង Medicare និងបញ្ហាសុខភាពណាមួយដែលលោកអ្នកអាចមាន)។ ទោះជាយ៉ាងណាក៏ដោយ គេនឹងរក្សាទុកព័ត៌មាននេះជាសម្ងាត់ ហើយត្រូវបានផ្តល់ជូន សម្រាប់តែសេវាដែលពាក់ព័ន្ធដោយមានការយល់ព្រមពីអ្នកប៉ុណ្ណោះ។

ប្រសិនបើលោកអ្នកត្រូវការតែសេវាកម្រិតមូលដ្ឋានមួយ ឬពីរ បុគ្គលិកនឹងផ្តល់ជូនលោកអ្នកនូវព័ត៌មានអំពីសេវានៅក្នុងតំបន់ជិតខាងលោកអ្នក។ ប្រសិនបើលោកអ្នកមានតម្រូវការខ្ពស់ លោកអ្នកនឹងត្រូវគេបញ្ជូនដើម្បីទទួលការវាយតម្លៃធ្វើឡើងដោយ Regional Assessment Service (សេវាវាយតម្លៃក្នុងតំបន់) ឬ Aged Care Assessment Team (ក្រុមវាយតម្លៃសេវាថែទាំមនុស្សចាស់) ក្នុងតំបន់លោកអ្នក។

ប្រសិនបើលោកអ្នកមិនមានអារម្មណ៍ថាមានទំនុកចិត្តគ្រប់គ្រាន់ដើម្បីទូរស័ព្ទទៅ My Aged Care Contact Centre ដោយខ្លួនឯងទេ លោកអ្នកអាចស្នើសុំសមាជិកគ្រួសារ សេវាក្នុងតំបន់លោកអ្នក ឬអង្គភាពពាក់ព័ន្ធណាមួយដើម្បីជួយលោកអ្នក។

## ប្រសិនបើលោកអ្នកត្រូវការប្រឹក្សាផ្នែកច្បាប់ ឬការគាំទ្របន្ថែមទៀត លោកអ្នកអាចទាក់ទង៖

- **Aged Care Complaints Commissioner:**
  (ស្នងការទទួលបណ្តឹងអំពីសេវាថែទាំមនុស្ស)
  **1800 550 552**
- **National Aged Care Advocacy Line:**
  (ខ្សែទូរស័ព្ទជាតិគាំទ្រសេវាថែទាំមនុស្សចាស់)
  **1800 700 600**
- **Senior Rights Service:** (សេវាគាំទ្រសិទ្ធិមនុស្សចាស់)
  **1800 424 079**

កម្មវិធីផ្តត់ផ្គង់លំនៅដ្ឋានសហព័ន្ធ

(COMMONWEALTH HOME SUPPORT PROGRAM)

# កម្រិតមូលដ្ឋាននៃសេវាថែទាំតាមផ្ទះ

មនុស្សមួយចំនួនអាចត្រូវការតែសេវាមួយ ឬពីរប៉ុណ្ណោះក្នុងចំណោមសេវាដូចខាងក្រោមនេះ ដើម្បីជួយពួកគេបំពេញការងារប្រចាំថ្ងៃ ឬទៅហាង ឬទៅជួបពេទ្យតាមការណាត់ជួប។ លោកអ្នកអាចផ្អាក និងចាប់ផ្តើមទទួលសេវានៅពេលណាមួយក៏បាន - ឧទាហរណ៍ លោកអ្នកអាចត្រូវការជំនួយសម្រាប់តែរយៈពេលខ្លី ប្រសិនបើលោកអ្នកមិនស្រួលខ្លួន។

## ប្រភេទនៃសេវា

- ការជួយធ្វើកិច្ចការតាមផ្ទះ - ជួយសម្អាតផ្ទះ បោកគក់ និងអ៊ុតសំលៀកបំពាក់
- ការថែទាំផ្ទាល់ខ្លួន - ជួយងូតទឹក ស្លៀកពាក់ឲ្យ និងការជូនទៅបង្គន់
- ការថែទាំ - ការថែទាំផ្នែកពេទ្យចាំបាច់ ដូចជាការរុំបិទរបួស ឬការជួយរៀបចំថ្នាំពេទ្យ
- ម្ហូបអាហារ - ការដឹកបញ្ជូនអាហារ រួមមានរបបអាហារពិសេស
- ការដឹកជញ្ជូន - សម្រាប់ទៅផ្សារទិញឥវ៉ាន់ ឬការណាត់ជួប
- ការគាំទ្រផ្នែកសង្គម - ជូនលោកអ្នកទៅផ្សារទិញឥវ៉ាន់ ទៅធនាគារ ឬទៅចូលរួមក្នុងសកម្មភាពផ្នែកសង្គម
- ការមើលថែផ្ទះ - ការជួសជុសបន្តិចបន្តួច និងថែទាំផ្ទះរបស់លោកអ្នក ដូចជាការប្តូរអំពូលភ្លើង ការប្តូរទ្រនាប់ក្បាលរ៉ូប៊ីណេ ឬការកាត់ស្មៅ
- ការកែលម្អផ្ទះ - ការដំឡើងឧបករណ៍ជំនួយសុវត្ថិភាព ដូចជាឧបករណ៍ប្រកាសអាសន្ននៅពេលមានផ្សែង ជណ្តើរឡើងទួល និងបង្កាន់ដៃទ្រនៅក្នុងផ្ទះរបស់លោកអ្នក
- ការថែទាំជំនួសបណ្តោះអាសន្នដែលអាចបត់បែនបាន - ទទួលបានការថែទាំជំនួសបណ្តោះអាសន្ន ដើម្បីឲ្យអ្នកថែទាំទៀងទាត់របស់លោកអ្នកអាចមានពេលឈប់សម្រាក
- សម្ព័ន្ធសុខភាព - សេវាអ្នកជំនាញផ្នែកសុខភាពក្រៅពីវេជ្ជបណ្ឌិតរបស់លោកអ្នក ដូចជាគ្រូពេទ្យព្យាបាលដោយចលនា គ្រូពេទ្យជំនាញព្យាបាល ជើង  គ្រូពេទ្យព្យាបាលដោយសកម្មភាពផ្សេងៗ ឬអ្នកជំនាញខាងរបបអាហារ
- គ្រឿងបរិក្ខាពិសេស - បរិក្ខាទាំងឡាយដូចជាគ្រោងឈើសម្រាប់ជំនួយដើរ  និងកៅអីងូតទឹក ដែលបង្កលក្ខណៈកាន់តែងាយស្រួលសម្រាប់មនុស្សរស់នៅដោយឯករាជ្យតាមផ្ទះ

## ការវាយតម្លៃ

My Aged Care Contact Centre នឹងបង្កើតកំណត់ត្រាអតិថិជន ហើយកត់ត្រាព័ត៌មានលម្អិត និងតម្រូវការផ្ទាល់ខ្លួនរបស់លោកអ្នក។ ព័ត៌មាននេះនឹងត្រូវបានរក្សាទុកជាសម្ងាត់ ហើយត្រូវបានផ្តល់ជូនតែសេវាដែលពាក់ព័ន្ធដោយមានការយល់ព្រមពីលោកអ្នកប៉ុណ្ណោះ។ បុគ្គលិក Contact Centre នឹងពិភាក្សាពីជម្រើសខ្លះៗជាមួយលោកអ្នក។ នេះអាចមានរួមទាំងការបញ្ជូនដើម្បីទទួលការវាយតម្លៃលើការផ្គត់ផ្គង់តាមផ្ទះ ដោយ Regional Assessment Service ក្នុងតំបន់លោកអ្នក។

## ការចំណាយ

រាល់ការចំណាយត្រូវមានការព្រមព្រៀងគ្នាជាមួយអង្គភាពនីមួយៗ មុនពេលលោកអ្នកទទួលបានសេវាថែទាំមនុស្សចាស់ណាមួយ។ លោកអ្នកនឹងត្រូវគេស្នើសុំរួមវិភាគទានដល់ការចំណាយលើសេវា។ ការចំណាយនេះនឹងប្រែប្រួលអាស្រ័យលើសេវាដែលលោកអ្នកទទួលបាន។

កញ្ចប់ថែទាំតាមផ្ទះ

(HOME CARE PACKAGES)

# កម្រិតខ្ពស់នៃការថែទាំតាមផ្ទះ

Home Care Package គឺជាសេវាសម្របសម្រួលដែលបានបង្កើតឡើងដើម្បីបំពេញតាមតម្រូវការជាក់លាក់របស់លោកអ្នក។ កញ្ចប់សេវាត្រូវ បានផ្តល់ជូនក្រោមប្រព័ន្ធមួយដែលគេស្គាល់ថា Consumer Directed Care (សេវាថែទាំតម្រូវតាមអតិថិជន) ជាផ្នែកមួយនៃ My Aged Care។ Consumer Directed Care ផ្តល់ជូនលោកអ្នកនូវជម្រើសកាន់តែច្រើនលើប្រភេទនៃសេវា និងការថែទាំសម្រាប់លោកអ្នក។

មានកម្រិតនៃការផ្គត់ផ្គង់បួន អាស្រ័យលើតម្រូវការរបស់លោកអ្នក៖

- កម្រិតមូលដ្ឋាន
- កម្រិតទាប
- កម្រិតមធ្យម
- កម្រិតខ្ពស់

## ប្រភេទនៃសេវា

- សេវាថែទាំផ្ទាល់ខ្លួន ដូចជាការងូតទឹកផ្កាឈូក ឬងូតទឹក។
- សេវាផ្គត់ផ្គង់ដូចជា ការសម្អាតផ្ទះ ការបោកគក់ និងអ៊ុតខោអាវ ការថែទាំសួន ការថែទាំផ្ទះ និងសេវាដឹកជញ្ជូនទៅទិញឥវ៉ាន់ ទៅជួបវេជ្ជបណ្ឌិត ឬទៅចូលរួមសកម្មភាពផ្នែកសង្គម។
- សេវាថែទាំព្យាបាល៖ ការថែទាំព្យាបាល និងប្រភេទផ្សេងទៀតនៃសេវាគាំទ្រផ្គត់ផ្គង់សុខភាព ដូចជាសេវាគ្រូពេទ្យព្យាបាលដោយចលនា ឬអ្នកជំនាញរបបអាហារ។

## ការវាយតម្លៃ

My Aged Care Contact Centre នឹងបង្កើតកំណត់ត្រាអតិថិជន ហើយកត់ត្រាព័ត៌មានលម្អិត និងតម្រូវការផ្ទាល់ខ្លួនរបស់លោកអ្នក។ ព័ត៌មាននេះនឹងត្រូវបានរក្សាទុកជាសម្ងាត់ ហើយត្រូវបានផ្តល់ជូនតែសេវាដែលពាក់ព័ន្ធដោយមានការយល់ព្រមពីលោកអ្នកប៉ុណ្ណោះ។ បុគ្គលិក Contact Centre នឹងពិភាក្សាពីជម្រើសខ្លះៗជាមួយលោកអ្នក។ នេះអាចមានរួមទាំងការបញ្ជូនដើម្បីទទួលការវាយតម្លៃលើការផ្គត់ផ្គង់តាមផ្ទះ។ Aged Care Assessment Team នឹងធ្វើការវាយតម្លៃនៅក្នុងផ្ទះរបស់លោកអ្នក ដើម្បីកំណត់លើតម្រូវការរបស់លោកអ្នក។

## ការចំណាយ

រដ្ឋាភិបាលអូស្ត្រាលីផ្គត់ផ្គង់ប្រាក់ឧបត្ថម្ភចំនួនផ្សេងៗគ្នាសម្រាប់កម្រិតនៃកញ្ចប់សេវាថែទាំនីមួយ។ លោកអ្នកនឹងត្រូវរួមវិភាគទានខ្លះ ក៏ប៉ុន្តែការរួមវិភាគទានរបស់លោកអ្នកត្រូវមិនលើសពី១៧.៥ភាគរយ នៃប្រាក់សោធនផ្ទាល់ខ្លួនរបស់លោកអ្នកទេ។

ក្រសួងសេវាមនុស្សសាស្ត្រ នឹងធ្វើការវាយតម្លៃលើស្ថានភាពផ្នែកហិរញ្ញវត្ថុរបស់លោកអ្នក។ តម្លៃនៃផ្ទះ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់លោកអ្នកមិនត្រូវបានគេគិតបញ្ចូលនៅក្នុងការវាយតម្លៃនេះទេ។

ប្រសិនបើលោកអ្នកជឿថា ការចំណាយលើសេវាថែទាំមនុស្សចាស់នឹងធ្វើឲ្យលោកអ្នកមានការលំបាកផ្នែកហិរញ្ញវត្ថុ លោកអ្នកអាចស្នើសុំឲ្យគេពិចារណាដើម្បីផ្តល់ជំនួយផ្នែកហិរញ្ញវត្ថុ។

ការថែទាំដែលមានលក្ខណៈតាមលំនៅដ្ឋាន
(RESIDENTIAL CARE)

# ការថែទាំអចិន្ត្រៃយ៍២៤ម៉ោង ឬសេវាថែទាំរយៈពេលខ្លី

## ប្រភេទនៃសេវា

សេវាថែទាំមនុស្សចាស់មានលក្ខណៈតាមលំនៅដ្ឋានផ្តល់នូវជម្រើសថែទាំជាច្រើនភេទ និងកន្លែងស្នាក់នៅសម្រាប់មនុស្សចាស់ដែលមិនអាចបន្តការរស់ដោយឯករាជ្យម្ចាស់នៅក្នុងផ្ទះរបស់ខ្លួន។

ប្រសិនបើនរណាម្នាក់ដែលលោកអ្នកថែទាំត្រូវការជំនួយរាល់ថ្ងៃ គេអាចត្រូវការការស្នាក់នៅរយៈពេលខ្លីនៅតាមផ្ទះថែទាំមនុស្សចាស់ដើម្បីឲ្យក្រុមគ្រួសារអាចមានពេលសម្រាក។ ការថែទាំនេះហៅថា ការថែទាំជំនួសបណ្តោះអាសន្នមានលក្ខណៈតាមនៅលំនៅដ្ឋាន។ ប្រភេទនៃការថែទាំនេះអាចរៀបចំគ្រោងទុកជាមុនបាន ក៏ប៉ុន្តែក៏អាចផ្តល់ជូនក្នុងគ្រាអាសន្នបានដែរ។

ផ្ទះថែទាំមនុស្សចាស់អាចជួយ៖

- ការថែទាំផ្ទាល់ខ្លួន៖ ដូចជាការស្លៀកពាក់ឲ្យ ការតុបតែងខ្លួន និងការជូនទៅបង្គន់
- ការងារប្រចាំថ្ងៃ ដូចជាការសម្អាត ការចម្អិនអាហារ ឬការបោកគក់សម្លៀកបំពាក់
- ការថែទាំ២៤ម៉ោង ក្រោមការត្រួតពិនិត្យពីគិលានុបដ្ឋាកដែលចុះបញ្ជីស្របច្បាប់
- លទ្ធភាពបានសេវាផ្សេងទៀត ដូចជាការព្យាបាលដោយចលនា ឬការព្យាបាលជើង

## ការវាយតម្លៃ

ដើម្បីមានសិទ្ធិទទួលបានសេវាថែទាំដែលមានលក្ខណៈតាមលំនៅដ្ឋានក្រោមការឧបត្ថម្ភពីរដ្ឋាភិបាលអូស្ត្រាលី ជាដំបូង លោកអ្នកត្រូវបានរដ្ឋទទួលយល់ព្រមថាជាអ្នកទទួលការថែទាំ។ Aged Care Assessment Team នឹងធ្វើការវាយតម្លៃលើសិទ្ធិទទួលបាន និងតម្រូវការថែទាំរបស់ លោកអ្នក។

## ការចំណាយ

- **តម្លៃប្រចាំថ្ងៃ** (៨៥ភាគរយនៃអត្រាប្រាក់សោធនមូលដ្ឋានសម្រាប់មនុស្សម្នាក់)។ នៅពេលលោកអ្នកចូលផ្ទះថែទាំមនុស្សចាស់ លោកអ្នកនឹងទទួលបានលិខិតមួយច្បាប់ពីក្រសួងសេវាមនុស្សសាស្ត្រ ដែលបញ្ជាក់ពីថ្លៃសេវាមូលដ្ឋានប្រចាំថ្ងៃអតិបរមារបស់លោកអ្នក។ ថ្លៃសេវាប្រចាំថ្ងៃគ្របដណ្តប់ការចំណាយលើការរស់នៅដូចជាម្ហូបអាហារ ការបោកគក់ និងសេវាថែទាំទូទៅ។
- ការបង់ថ្លៃស្នាក់នៅ គឺសម្រាប់កន្លែងស្នាក់នៅរបស់លោកអ្នកនៅក្នុងផ្ទះ។ ក្រសួងសេវាមនុស្សសាស្ត្រ នឹងគណនាថាតើលោកអ្នកត្រូវបានតម្រូវឲ្យ បង់ថ្លៃសេវានេះឬអត់ ដោយផ្អែកលើប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់លោកអ្នក។ ប្រសិនបើលោកអ្នកត្រូវបង់ការបង់ថ្លៃស្នាក់នៅនេះនឹងត្រូវ មានការយល់ព្រមជាមួយនឹងផ្ទះថែទាំមនុស្សចាស់។ មនុស្សមួយចំនួននឹងត្រូវរដ្ឋាភិបាលអូស្ត្រាលីជួយបង់ថ្លៃស្នាក់នៅពេញចំនួន ហើយអ្នកផ្សេង ទៀតនឹងត្រូវបង់ថ្លៃស្នាក់នៅដោយខ្លួនគេ។
- ជម្រើសសេវាបន្ថែមទៀត៖ ថ្លៃសេវាទាំងនេះអាចត្រូវអនុវត្ត ប្រសិនបើលោកអ្នកជ្រើសរើសយកស្តង់ដាកម្រិតខ្ពស់នៃការស្នាក់នៅ ឬសេវាបន្ថែម។

**Get to know the Australian Aged Care System 2016**

A partnership of the Multicultural Access Project Network, and the Multicultural Aged Officer South Western Sydney.
The Multicultural Access Projects receive funding from the Department of Social Services.
**Reference:** Australian Department of Social Services, www.**myagedcare**.gov.au

*Printed by Fairfield City Council.*